សៀវភៅសំរាប់សិក្សា

ឌ.គាម

និពន្ធ

# សម្ពន្ធខ្មែរ

មធ្យមដ្ឋាន និង ឧត្ដមដ្ឋាន

សម្រាប់គ្រូ និង សិស្ស

# ANALYSE KHMERE

ផ្សាយចេញពី

…ណ្ណាគារ សេង-ងួន-ហួត

…លេខ ៦៧ វិថីព្រះបាទទបន្ទាភជា (ភ្នំពេញ)

…ព.ស. ២៥០០ គ.ស. ១៩៥៧

រក្សាសិទ្ធិ

413
ARCHIVES NATIONALES
REÇUS AU DÉPÔT LÉGAL
ARCHIVES
COTE

# អារម្ភកថា

ការធ្វើរបស់ខ្ញុំជាដំបូង តែងមានឧបសគ្គ ៗ សៀវភៅសម្ពន្ធខ្មែរនេះ ខ្ញុំដកយកតាមក្បួនសម្ពន្ធបាលីខ្លះ បារាំងខ្លះ ៗ របៀបណាដែលខ្ញុំអាចដាក់ឲ្យឆាប់យល់ ខ្ញុំត្រូវដំរូវទៅតាមរបៀបនោះ ដូច្នេះពាក្យណាដែលខ្ញុំហៅមុន ដូចថា សត្តមីកម្ម Complément circonstanciel de lieu ជាដើម ៗ ក្នុងសត្តមីវិភត្តិបាលី គេអាចសម្ពន្ធបាន ៩ យ៉ាង បើយកទាំង ៩ មកនិយាយពិបាកណាស់ ដូច្នេះ ចាំទៅថ្នាក់ខ្ពស់សឹមរៀនឲ្យអស់ ៗ

ខ្ញុំសូមឲ្យលោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស មេត្តាជួយតម្រង់សម្ពន្ធខ្មែរនេះឲ្យបានស្រួលផង បើយល់ទាស់សូមជួយឲ្យខ្ញុំផង ដើម្បីឲ្យក្បួនសម្ពន្ធយើងមានរបៀបរៀបរយ ៗ

ឱ - គាម

សិស្សសាលាបាលីជាន់ខ្ពស់

សិស្សវិទ្យាល័យស៊ីសុវត្ថិ

## ជំពូកទី ១

# របៀបសម្ពន្ធ

### មេរៀនទី ១

គ្រូ សម្ពន្ធខ្មែរ មានន័យប្រហែលនឹងសម្ពន្ធបាលី ដែរ តែខ្ញុំមិនបាននិយាយឲ្យវែងដូចសម្ពន្ធបាលីឡើយ ព្រោះថាថ្នាក់បឋមសិក្សា យើងត្រូវបង្រៀនសម្ពន្ធដំបូង គឺ នាម, គុណនាម, កិរិយា, នឹងនិបាតខ្លះ ៗ

សម្ពន្ធខ្មែរ និយាយឲ្យខ្លី ដើម្បីឲ្យងាយចូលចិត្ត គេ ចែកសម្ពន្ធជាពីរបែបគឺ

១– សម្ពន្ធសព្ទ Analyse grammaticale

២– សម្ពន្ធប្រយោគ Analyse logique

តែមុននឹងរៀនសម្ពន្ធត្រូវរៀនឲ្យចេះពាក្យខ្លះជាមុនសិន ដើម្បីឲ្យងាយយល់ ងាយចូលចិត្ត គឺត្រូវរៀនពាក្យថា ឃ្លា នឹងប្រយោគ ៗ

ឃ្លា phrase គឺសង្កាត់ពាក្យដែលគេត្រូវដាក់ខណ្ឌមួយ ៗ ក្នុងឃ្លាមួយ ៗ មានមួយប្រយោគ ពីរប្រយោគ ឬច្រើនប្រយោគ ។

ឧ-១ ឪពុកខ្ញុំទៅស្រែ ។

២– ឪពុកខ្ញុំទៅស្រែ ឯម្ដាយខ្ញុំនៅផ្ទះ មើលកូន នឹងថែទាំផ្ទះ (ឧ.គ)

បំណាំ : ឃ្លាទី១ មានតែមួយប្រយោគ ។

ឃ្លាទី២ មាន ២ ប្រយោគ គឺ

ក– ឪពុកខ្ញុំទៅស្រែ (ប្រយោគទី១)

ខ– ឯម្ដាយខ្ញុំនៅផ្ទះ មើលកូននឹងថែទាំផ្ទះ (ប្រយោគទី២)

ប្រយោគ ប្រយោគ Proposition គឺដំណើរសេចក្ដីដែលមានសេចក្ដីពេញគ្រប់គ្រាន់ ។ ក្នុងប្រយោគ មានប្រធាន មានកិរិយា មានកម្ម..... ។

តែមានប្រយោគខ្លះគ្មានកិរិយាទេ

ខ – ១- ខ្ញុំជាកសិករ

២ – ខ្ញុំទៅសាលារៀន

ចំណាំ: ប្រយោគទី១ គ្មានកិរិយាទេ តែថាក្នុងបាលី គេទុកជាកិរិយាស័ព្ទ ។

ប្រយោគទី២ មានប្រធាន - មានកិរិយា - មានកម្ម រួមបានជាមួយប្រយោគ ។

ដើម្បីដឹងថា ក្នុងឃ្លាមួយ ៗ មានប៉ុន្មានប្រយោគនោះ តាមបាលីគេឲ្យសង្កេតមើលកិរិយាអាខ្យាត ឬសង្កេតមើលប្រធាន បើប្រធានមួយ គេថាមួយប្រយោគ បើប្រធាន ២ ដាច់សេចក្ដីពីគ្នា គេថាមានពីរប្រយោគដែរ ។ ជួនកាលប្រយោគខ្លះ មានប្រធានដល់ទៅពីរ តែកិរិយាសំរេចប្រយោគតែមួយ ។

សិស្ស————មេរៀន————

១– ឃ្លា : សង្កាត់ពាក្យដែលត្រូវដាក់ខណ្ឌមួយ ។

បំណាំ: ក្នុងមួយឃ្លា មានមួយប្រយោគ ឬច្រើនប្រយោគ ។

២-ប្រយោគ ដំណើររឿងក្តីដែលពេញគ្រប់គ្រាន់គឺ (ប្រធាន-កម្ម-កិរិយា)

ការហាត់ ក្នុងឃ្លាខាងក្រោមនេះមានប៉ុន្មានប្រយោគ

១- បងស្រីខ្ញុំមានប្តីហើយ

២- ពេលព្រឹកខ្ញុំទៅសាលារៀន បងខ្ញុំទៅធ្វើការឯការិយាល័យ ។

៣- ជីដូនខ្ញុំ អនិច្ចកម្មហើយ ។

៤- ស្គរដង្គុំម៉ឺង ៗ ! ខ្ញុំចូលទៅក្នុងថ្នាក់ កូនសិស្សខ្លះចូលក្រោយខ្ញុំ ឯលោកគ្រូចាំតែកូនសិស្សចូលអស់ទើបគាត់ចូល ។

៥- អ្នកលក់អង្គុយតែក្បែរពានគ្រី អ្នកទិញដើរប្រៀបប្រៀតចិនកាប់សាច់ជ្រូក យួនលក់បបរ ។

# ជំពូកទី ២

## សម្ពន្ធនាម

Analyse les Noms

### មេរៀនទី ២

— គ្រូ   សាធារណនាម   អសាធារណនាម

មុននឹងចាប់សម្ពន្ធនាម ត្រូវសង្កេតមើលថា តើនាមនេះឈ្មោះអ្វី ជាសត្វ, ជាមនុស្ស , ជាវត្ថុ, បើជាមនុស្ស ជាសត្វ ជាវត្ថុ តើមានគេឈ្មោះដូចនេះឬទេ បើថាមានទៀតដែរ ដែលមានឈ្មោះគេដូច្នេះនោះ នាមនេះ ហៅថា <u>សាធារណនាម</u> Nom Commun ។ បើនាមនោះ ប្រើបានតែឈ្មោះតែម្នាក់ទេ បើឈ្មោះមនុស្ស ក៏មនុស្សតែម្នាក់ សត្វក៏សត្វតែមួយ របស់ក៏របស់តែមួយ មិនទូទៅឈ្មោះឯទៀតដូច្នេះ ហៅថា <u>អសាធារណនាម</u> Nom propre

## របៀបសម្ពន្ធ

សាធារណនាម និងអសាធារណនាម ត្រូវសម្ពន្ធជាប្រធាន ជាកម្ម ។ តែអសាធារណនាមគ្មានពហុវចនៈទេ មានតែឯកវចនៈតែម្យ៉ាង ។

១- មានកុមារម្នាក់ឈ្មោះដាន់ ខស្វាហ៍រៀនសូត្រណាស់ ។ (គ. សែត)

២- លោកគ្រូបង្រៀន និងឪពុកម្ដាយកុមារនេះមានចិត្តសប្បាយរីករាយសង្ឃឹមយ៉ាងមាំថាៈ ដល់ដាច់ឆ្នាំ ដាន់ និងបានប្រឡងជាប់វិញ្ញាបនប័ត្រ ហើយបានទទួលអាហារូបករណ៍នៅវិទ្យាល័យស៊ីសុវត្ថិ ឯភ្នំពេញមិនខាន (គ. សែត)

### សម្ពន្ធ

| | |
|---|---|
| ដាន់ | អសាធារណនាម ឯកវចនៈ |
| លោកគ្រូបង្រៀន | សាធារណនាម " |
| ឪពុកម្ដាយ | សាធារណនាម " |
| វិទ្យាល័យស៊ីសុវត្ថិ | អសាធារណនាម " |
| ភ្នំពេញ | " " |

សិស្ស ——— មេរៀន ———

១- សាធារណនាម នាមដែលទូទៅ

២- អសាធារណនាម នាមដែលមិនទូទៅ

៣- សាធារណនាម នឹងអសាធារណនាម មានមុខ

៤- អសាធារណនាម ជាឯកវចនៈ

ការហាត់ ចូរសម្តន្ឌនាមខាងក្រោមនេះ (ជាសាធារណនាម ឬអសាធារណនាម)

១- សត្យថូផាន់ នៅរៀនឧត្តមដ្ឋាន

២- សិស្សខំយកចិត្តទុកដាក់នឹងគ្រូ ៗ

៣- គ្រូសប្បាយចិត្តណាស់ ដោយឃើញកូនសិស្សប្រឹងស្ដាប់ ៗ

៤- ដល់ពេលដាច់ឆ្នាំ សិស្សបានឡើងថ្នាក់ ៗ

មេរៀនទី ៣

## សម្ពន្ធលិង្គ

គ្រូ – លិង្គបើតាមភាសាបាលីមានដល់ទៅបីគឺ បុំលិង្គ ឥត្ថីលិង្គនិងនបុំសកលិង្គ តែចំពោះខ្មែរវិញពិបាកសំគាល់លិង្គណាស់ ដែលគេស្គាល់លិង្គទៅបានច្បាស់អាស្រ័យពាក្យគឺ បុរស - ស្ត្រី, ញី - ឈ្មោល, ហើយនិងពាក្យខ្លះទៀត ដែលជាជាតិលិង្គ ដូចជាប្រពន្ធ-ប្តី ពាក្យនេះគ្រាន់តែបេញមក គេអាចសម្ពន្ធបានថា បុំលិង្គ ឥត្ថីលិង្គ ៗ ឯភាសាបាលីវិញ មានវិភត្តិសំរាប់ឲ្យស្គាល់សមត្ថលិង្គ ដូចជា ហត្ថី បុំ · ហត្ថិនី ឥ· ជាដើម ៗ

ក្នុងវិធីសម្ពន្ធនាម ត្រូវស្គាល់ឲ្យច្បាស់ពាក្យនោះថាតើជាលិង្គអ្វី ៗ ប៉ុន្តែបើមានសព្ទដូចជា ( អា-បា-កម្លោះ-តា-ពូ-មា ) ទាំងនេះ គេអាចថាជាបុំលិង្គបានស្រួល ( មី-កា-ក្រមុំ-យាយ-ដូន-មីង ) គេអាចថាឥត្ថីលិង្គបាន ( ខ្ទើយ ) គេអាច

ថា នបុំសកលិង្គបាន ។

របៀបសម្ពន្ធ បើគេសម្ពន្ធនាមហើយគេត្រូវថាលិង្គ ជាបន្ទាប់ភ្លាម

ឧ – ១- ជីដូន មើលទៅហើយនិទានរឿងឲ្យចៅស្ដាប់ ។

២ – ពូហើយនឹងមីង ទៅចំការ ។

| សម្ពន្ធ | | |
|---|---|---|
| ជីដូន | សាធារណនាម | ឥត្ថីលិង្គ |
| មីង | សាធារណនាម | ឥត្ថីលិង្គ |
| ពូ | សាធារណនាម | បុំលិង្គ |

សិស្ស ——— មេរៀន ———

លិង្គមាន ៣ យ៉ាងគឺ

១–បុំលិង្គ ភេទប្រុស-ឈ្មោល (ពូ-មា-តា កំឡោះ-បា)

២– ឥត្ថីលិង្គ ភេទស្រី ញី (មេ-ក្រមុំ-យាយ-ដូន មី-កា-ហង្ស )

៣– នបុំសកលិង្គ គេទខ្ទើយ (មនុស្សខ្ទើយ)

៤– បើសម្ពន្ធនាមហើយ ត្រូវសម្ពន្ធលិង្គ

ការហាត់ ប្តូរសម្ពន្ធលិង្គរបស់នាមដែលនៅខាងក្រោម នេះ ។

១– កសិករលើនង្គ័លលើស្មា ដឹកក្របីឆ្ពោះទៅស្រែ (គ-ស)

២– នាងគាស់ដីបណ្ដើរ សម្រកទឹកភ្នែកបណ្ដើរ-ហូរ ជោកជាំ (ព្រះត្រពាំងបុត្រ)

៣– មាតាបិតាណាមិនឲ្យកូនទៅរៀន លុះដល់កូនធំ ឡើង កូននោះប្រព្រឹត្តអំពើពាល ទោសនោះត្រូវធ្លាក់មក លើបិតាមាតា (គ-ស)

៤– ស្វាឈ្មោលមួយចេញពីព្រៃមក បានជួបនឹងមេ អណ្ដើកចាស់ៗ ក្បែរមាត់ត្រពាំងទឹក ។

៥– គោបា កាលមេមិនឲ្យគោឈ្មោលទៅក្បែរគោញីៗ

មេរៀនទី ៤

## សម្ពន្ធវចនៈ

គ្រូ វចនៈរបស់ខ្មែរ មានដូចតែវចនៈបារាំង បាលីដែរ បំណែកសំស្ក្រឹតមានវចនៈ ៣ យ៉ាង ។ វចនៈ ២ យ៉ាងគឺ:

១– ឯកវចនៈ: គេសំគាល់មនុស្ស សត្វ វត្ថុតែមួយៗ តែឯកវចនៈ គេអាចសំគាល់បានឆាប់ ដោយមានពាក្យខ្លះជាគ្រឿងសំគាល់គឺ: (មួយ ម្នាក់ - ឯក - តោល - ម្ខាង) តែបើនាមចេញមកគ្មានពាក្យអ្វីភ្ជាប់ជាមួយ ដូចជា ក្របី - គោជាដើម គេអាចថា ឯកវចនៈបាន តែបើមានហ្វូងក្របី - គោ គេមិនថាឯកវចនៈទេ

២– ពហុវចនៈ: ពហុវចនៈរបស់ខ្មែរ បើសង្កេតទៅគួរឲ្យយល់បានដែរ ព្រោះថាមានពាក្យខ្លះដែលអាចឲ្យសំគាល់បានថា ពហុវចនៈ គឺ (ពួក, ទាំងឡាយ - ទាំងអស់ - សព្វ

តាំងតួង-ហ្វូង-ក្រុម.....)

ចំណាំ ភាសាបាលីសំស្ក្រឹតងាយចំណាំណាស់ ព្រោះភាសានេះ មានវិភត្តិដែលអាចឲ្យសំគាល់បានថាជាឯកវចនៈ ពហុវចនៈបាន

ឧ–មនុស្ស (ឯ.) មនុស្សា (ពហុ)

សាមណេរ (ឯ.) សាមណេរា (ពហុ)

របៀបសម្ពន្ធ

គេមើលនាម បើមានពាក្យដូចបានពោលមកហើយ គេអាចសម្ពន្ធថា ឯកវចនៈ ឬពហុវចនៈបាន ដោយលើកស័ព្ទនោះធ្វើជាសំនួរថា ប៉ុន្មាន? បើតែមួយទេ ត្រូវសម្ពន្ធថា ឯកវចនៈ បើច្រើនថាពហុវចនៈ:

១– កុមារម្នាក់នេះ អង្គុលធ្មេញ ឈ្មោលមួយដោយសេចក្តីស្រឡាញ់ (ឧ.គ) ។

២– កុមារទាំងឡាយ អង្គុលធ្មេញ ឈ្មោលបួនដោយសេចក្តីពេញចិត្ត ។ (ឧ.គ)

៣– ពេលសំគាល់ឃើញ កុមារ កុមារី ចេញប្រឡែងគ្នា ក្នុងទីធ្លា (ឃ.គ) ។

——————— សម្ពន្ធ ———————

| | |
|---|---|
| ម្នាក់ | បទវិសេសន៍ របស់កុមារ ប្ញ-ឯកវចនៈ |
| មួយ | បទវិសេសន៍ របស់ធ្នា ប្ញ-ឯក. |
| ទាំងឡាយ | បទវិសេសន៍ របស់កុមារ ប្ញ-ពហុ. |
| ប្អូន | បទវិសេសន៍ របស់កុមារ ប្ញ-ពហុ |
| ចំណាំ | វចនៈទាំង២ត្រូវមានលិង្គ ដូចនាមដែរ ព្រោះហេតុនោះ |

ត្រូវសម្ពន្ធជាបទវិសេសន៍ របស់នាម ដែលវចនៈទាំងពីរនោះ ត្រូវសម្ពន្ធចូល ។

សិស្ស ——— មេរៀន ———

វចនៈ ២ យ៉ាងគឺ:

១– ឯកវចនៈ ប្រាប់មនុស្ស សត្វ-វត្ថុ តែមួយ ៗ ត្រូវបំណាំដោយពាក្យនេះគឺ (មួយ ម្នាក់-ម្ចាស់-តោល-ឯក)

២– ពហុវចនៈ ប្រាប់មនុស្ស សត្វ-វត្ថុ ដែលច្រើនៗ

ត្រូវបំណាំដោយពាក្យនេះគឺ ( ទាំងអស់-ទាំងឡាយ-សព្វ , ៗ ទាំងពួង-ហ្វូង-ច្រើន-ពួក )

៣– វចនៈ ទាំងពីរត្រូវសម្ពន្ធបួលជាមួយនាម បើនាមមានលិង្គដូចម្ដេច វចនៈក៏មានលិង្គដូច្នោះដែរ ។

ការហាត់ ចូរសម្ពន្ធនាមទាំងអស់ខាងក្រោមនេះ ( ឯក-ពហុ. )

១– អ្នកបររទេះឮដូច្នោះ ក៏ខំវាយគោទាំងឡាយ ហើយប្រានគង់តែម្នាក់ឯងយ៉ាងពេញទំហឹង ដោយនឹកសង្ឃឹមថាគេជួយ . . . ( ឱ.គ ) ។

២– គាត់ខំប្រហារគោទាំងទ្វេអស់ទំហឹង . . .

៣– ព្រឹក្សាដែលដុះក្នុងព្រៃមិនដូចគ្នាទេ ។

៤– មច្ឆា ហែបហែលក្នុងទន្លេ ដោយសេរី ។

៥– ព្រះរាជាមួយព្រះអង្គ សោយរាជសម្បត្តិ

## មេរៀនទី ៩

### ប្រធាន-កម្ម

Sujet - Complément

ក្រូ ១– នាមឬសព្វនាម ដែលជាម្ចាស់អ្នកធ្វើអំពើក្នុងប្រយោគ ហៅថាប្រធាន ។

២– នាមឬសព្វនាម អាចធ្វើជាបទកម្ម ទទួលរងអំពើរបស់ប្រធាន ដែលធ្វើអំពើ ហៅថា កម្ម ឬវត្ថុកម្ម ។

៣– ប្រធានខ្មែរ ច្រើនតែរៀងនៅខាងដើមប្រយោគ ឬក៏រៀងនៅបន្ទាប់ និបាតខ្លះដែលត្រូវរៀងនៅដើមប្រយោគ។ ប្រធានរៀងនៅចុងប្រយោគនោះ មានចំនួនតិចណាស់ ។

ចំណាំ ក្នុងភាសាបាលី បើមានពាក្យប្រែថា (រី) មុខតែជាប្រធានហើយ ចំណែកខ្មែរវិញ បើប្រែថា (រី) ត្រូវបាត់សម្ពន្ធជាប្រធាន ឬបើនៅដើមប្រយោគ ត្រូវថាជាប្រធាន ។

### របៀបសម្ពន្ធ

១– ប្រធានត្រូវសម្ពន្ធ តាមនាមឬសព្វនាម បើនាម

និងសព្វនាមជាសាធារណៈ អសាធារណៈ មានលិង្គ វចនៈ ដូចនាមនិងសព្វនាម ។

២- កម្មត្រូវសម្ពន្ធបន្ទាប់ពីកិរិយាដែលធ្វើនូវអំពើ ។ កម្មដែលសម្ពន្ធជាមួយកិរិយា ទទួលរងអំពើ ( វត្ថុកម្ម - កម្ម Complément )

ដើម្បីសួររកនាមជាប្រធាន ឬកម្មនេះត្រូវសួរបញ្ជាក់មុខងាររបស់នាម

១-ក ) បើមនុស្សនិងសត្វ ដើម្បីសួររកប្រធាន ត្រូវសួរខ្លួនឯងថា « នរណាធ្វើនូវអំពើ ?

ឧ- ដូចប្រយោគខាងក្រោម

នរណាឮពាក្យ ?

គោបាល ឮពាក្យ

ដូច្នេះ គោបាល ជាប្រធាន

ខ ) បើជាវត្ថុ សួរថា « អ្វីធ្វើអំពើនោះ ?

២– កម្មវត្ថុ ត្រូវសួរថា «ធ្វើនូវអ្វី?

១–គោបាលធ្វើ នូវអ្វី?

គោបាលធ្វើពាក្យ

ដូច្នេះ ពាក្យជាកម្ម របស់ធ្វើ

១–គោបាលធ្វើនូវពាក្យសច្ចាប្រណិធានរបស់កំរុយោម៉ឺនម៉ាត់ដូច្នោះ ធេះដូចក្មេង (ប៉. ខាត់)

២– ខ្ញុំបានឃើញនាងកញ្ញាអង្គុយលើទែនសយនាដ៏ល្អនោះមែន (ប៉. ខាត់)

សម្ពន្ធ

| | | |
|---|---|---|
| គោបាល | សាធារណនាម | ប៉ុំ - ឯក - ប្រធាននៃធ្វើ |
| នូវពាក្យ | សាធារណនាម | នប៉ុំ (១) -ឯក-កម្មរងនៃកិ.ធ្វើ។ |
| ខ្ញុំ | បុរិសព្ទ. | ប៉ុំ. ឯក. ប្រធាននៃបានឃើញ |
| កញ្ញា | បុរិសព្ទ. | ឥត្ថី. ឯ. កម្មនៃកិ. បានឃើញ |

បំណាំ នៅមុខបទកម្មខ្លះមានអាយតនិបាត (នូវ) តែខ្មែរច្រើនតែកាត់ចោល

១– បានជាជានប៉ុំ. ព្រោះបាលីជានប៉ុំ.ដែរ ។

ខ- ខ្មែរ ១- ខ្ញុំឲ្យទាន

ឃ- ខ្ញុំឲ្យនូវទាន

សិស្ស ______________ មេរៀន ______________

១– ពាក្យដែលជាប្រធាន គឺនាមនឹងសព្វនាម

២– នាមនឹងសព្វនាម អាចធ្វើជាកម្មផង ។

៣– ធម្មតា ប្រធានត្រូវរៀងនៅដើមប្រយោគ

៤- ប្រធានត្រូវសម្ពន្ធមុនគេក្នុងប្រយោគ

៥– តាមធម្មតា កម្មត្រូវរៀងបន្ទាប់កិរិយាសព្ទហើយ សម្ពន្ធបន្ទាប់កិរិយាសព្ទ ។

ការហាត់ ប្ដូរសម្ពន្ធប្រធាននឹងកម្មក្នុងប្រយោគខាងក្រោមនេះ

១– កូនសិស្ស មើលសៀវភៅ ។

២– ឆ្មាចាប់កណ្ដុរ ឆ្កែចាំផ្ទះ ។

៣– បុគ្គលបានដឹងច្បាស់នូវហេតុការណ៍ដូច្នេះសព្វគ្រប់ ហើយ គប្បីចាត់ចែងនូវការងារឲ្យមានរបៀបរៀបរយតទៅ

ទាន់មានឱកាសល្អ » (ប៉. ខាត់)

៤– ដោយច្រើន អាមាត្យកាន់នូវអំណាច បើគេសង្កត់តែត្បិត ទើបធ្វើឲ្យចំរើននូវព្រះរាជទ្រព្យនៃម្ចាស់ផែនដី ប្រៀបដូចបូសកាច បើគេច្របាច់ទើបខ្ទុះចេញ (ប៉-ខាត់)

## មេរៀនទី ៦

### អាយតនិបាត

ក្រ អាយតនិបាតបាលី លោកចែកជា ៨ យ៉ាង តែចំពោះថ្នាក់បឋមសិក្សាជាន់ដំបូង គ្រូតែរៀនអាយ-តនិបាតតែពីរសិនឲ្យស្គាល់ គ្រាន់ដល់ទៅថ្នាក់លើ ៗ សឹមរៀនតទៅទៀត ។ អាយតនិបាតដែលយកមករៀបរៀងនេះ ព្រោះឃើញមានប្រើច្រើនជាងគេ :

១– ទុតិយាវិភត្តិ ត្រូវប្រាប់នូវកម្ម (Complément d'objet direct )

២– សត្តមីវិភត្តិ អាយតនិបាតប្រាប់ទី (Complément circonstanciel de lieu

របៀបសម្ពន្ធ

១–មុននឹងសម្ពន្ធបទកម្ម ត្រូវមើលពាក្យដែលនៅខាងដើមនាមឬសព្វនាមសិន ពាក្យដែលត្រូវចំណាំ ទុតិយាវិភត្តិ

គឺ (នូវ-កាន់-ញាំង-អស់-ទឹង-ចំពោះ) ខ្ញុំឲ្យនូវបាន...

កំណត់ ផ្នួនកាលនៅដើមពាក្យខ្លះគ្មានអាយតនិបាតទេ តែមើលបើចង់ដណ្ដឹងសួរត្រូវចាប់យកកិរិយាក្នុងប្រយោគនោះមក ដណ្ដឹងសួរទើបឃើញថាជាបទកម្ម

ឧ- ខ្ញុំឲ្យបាន

២- ដើម្បីទឹងសម្ពន្ធសត្តមីវិភត្តិ ត្រូវដឹងថាសត្តមីច្រើនតែប្រាប់ទី-កន្លែង ៗ ក្នុងភាសាបាលីគេឲ្យសម្ពន្ធក៏បែប តែសម្ពន្ធខ្មែរ ខ្ញុំសន្មតថា សត្តមីកម្ម ដើម្បីឲ្យកុមារកុមារី ងាយចាំ ៗ ពាក្យដែលត្រូវបេះគឺ (ក្នុង, ឰដ៏, ត្រង់-នា, នាកាល, កាលបើ, កាលដែល, និមិត្ត, ជំនំ, បណ្ដា, លើ, ទៀប, ជិត)

បំណាំ គេមិនច្រើនយកសត្តមីមកនិយាយជាមួយទេ

ឧ- ខ្ញុំនៅផ្ទះ

គេកាត់ចោលអស់អាយតនិបាត ក៏អាចស្ដាប់បាន ។

៣- សត្តមីវិភត្តិ ត្រូវសម្ពន្ធចូលជាមួយកិរិយាសព្ទ ៗ

១- ពេលវស្សមកាល និស្សិត រៀបចំសៀវភៅទាំង

ឡាយដាក់ក្នុងហិប ហើយដើរទៅទៀបរថយន្តដើម្បីធ្វើដំណើរទៅមាតុភូមិ ។

២– និមន្តសាលាបិទទ្វារមុនចេញដំណើរទៅផ្ទះ លោកគ្រូឲ្យនូវឱវាទដល់សិស្ស ។

៣– អាកាសយាន ហោះពួដំអាកាស ។

សម្ពន្ធ

| | |
|---|---|
| សៀវភៅ | សាធារណនាម ន·លិង្គ ពហុវចន.កម្មវងនៃរៀបចំ |
| ក្នុងហិប | សាធារណនាម នបុំ. ឯកវចនៈសត្តមីកម្ម ក្នុង កិ–ដាក់ |
| ទៀបរថយន្ត | សាធារណនាម នបុំ. ឯក. សត្តមីកម្មក្នុង ដើរ |
| មាតុភូមិ (១) | សាធារណនាម ឥត្ថី – ឯក. កម្មវងនៃកិ–ទៅ |
| និមន្តសាលា | សាធារណនាម ឥត្ថី – ឯក.សត្តមីកម្មក្នុងបិទ |
| នូវឱវាទ | សាធារណនាម បុំ. ឯក កម្មវងគេឲ្យ |
| ពួដំអាកាស | សាធារណនាម បុំ. ឯក សត្តមីកម្មក្នុងហោះ |

១– បានជាហៅថាកម្មវង ព្រោះគេអាចថាទៅកាន់ផ្ទះ តែបើឲ្យស្រួលជាសត្តមីកម្មក៏បានដែរ "ទៅឯផ្ទះ" ប្រាប់ទី ផ្ទួនកាលនៅក្បែរប្រយោគ ដែលសត្តមីកម្ម ត្រូវសម្ពន្ធចូល ។

សិស្ស ________________ មេរៀន ________________

១- ទុតិយាវិភត្តិ ត្រូវប្រើជាបទកម្ម (នូវ-កាន់-ញុំាង អស់-ទីង-បំពោះ)

២- សត្តមីវិភត្តិ - អាយតនិបាតប្រាប់ទី (ក្នុង-ក្នុង-ត្រង់ នា-នាកាល-កាលបើ-ដ៏នុំ-និមិត្ត, លើ-ទៀប-ជិត)

៣- បទកម្មត្រូវរៀងនៅបន្ទាប់កិរិយា ដែលបទកម្មត្រូវ សម្ពន្ធឬល ។

៤- សត្តមីវិភត្តិ ដូនកាលនៅដើមប្រយោគ

ការហាត់ ក) ចូរសម្ពន្ធនាមជាកម្មរុង និងជាសត្តមីកម្ម ក្នុងប្រយោគ ខាងក្រោមនេះ

១- ឯចៅព្រានជាប្តី មុជក្លួបទៅក្នុងទឹក ទៅប៉ះទីង ជន្ទត់ បែកក្អែកឈើពន់ពេក ។

២- ព្រាន ខំវ៉ាះឡើងមកលើគោក រកខោមិនឃើញ ព្រោះខ្យល់បក់ក្លួចយកទៅ ។

៣– ផនទាំងពីរ ក៏ដល់ នូវសេចក្ដីវិនាស ។

២- បូរសម្ពន្ធនាមនឹងសព្វនាមក្នុងប្រយោគខាងក្រោមនេះ

១– ម្ចាស់សំណាប មកឃើញនូវទន្សាយ អរណាស់ ដោះទន្សាយដាក់ក្បែរខ្លួន រៀបដាក់អន្ទាក់ទៅវិញទន្សាយ បោលផ្លោះរត់ចូលក្នុងព្រៃបាត់

២– កាលបើខ្មោចឆេះស្អុះហើយ គេលត់ភ្លើងរើសនូវ ធាតុដាក់ក្នុងកោដ្ឋយកទៅបញ្ចុះទុកក្នុងអារាម ។

៣– គេដាក់ខ្មោចនៅក្នុងក្ដារមឈូស ។

# ជំពូកទី៣

## មេរៀនទី ៧

## សម្ពន្ធគុណនាម

Analyse les adjectifs

ត្រូវ មុននឹងសម្ពន្ធគុណនាម ត្រូវឲ្យស្គាល់គុណនាមទាំង ៣ សិន គឺបកតិគុណនាម វិសេសគុណនាម នឹងអតិវិសេសគុណនាម

១– បកតិគុណនាម គឺគុណនាមដែលសំដែងលក្ខណៈរបស់នាមតាមធម្មតា គ្មានពាក្យណាមួយនៅជាមួយបទគុណទេ

ឧ– ឆ្កែខ្មៅ

១– វិសេសគុណនាម គឺគុណនាមដែលសំដែងលក្ខណឲ្យលើកជាងបកតិគុណនាមបន្តិច ៗ ពាក្យសម្រាប់សំដែងឲ្យដឹងថាជាវិសេសគុណនាមគឺ (ជាង–លើស–លើក–វិសេស)ៈ

ពាក្យទាំងនេះ ត្រូវនៅខាងចុងគុណនាម ។

៤- គ្រប់ធំជាងគេ

៣- អតិវិសេសគុណនាម គឺគុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យប្លែកបំផុតទៅទៀត ។ ពាក្យសំរាប់ឲ្យស្គាល់ថាជាអតិវិសេសគុណនាមគឺ (បំផុត, ណាស់-យង់ក្រាស-ស្គុស-បណ្ដាច់-ចំឡែក) ។ ពាក្យទាំងនេះ ត្រូវនៅចុងគុណនាម

របៀបសម្ពន្ធ

១- គុណនាម ត្រូវជាបទវិសេសន៍របស់នាម ត្រូវតែសម្ពន្ធបុលជាមួយនាម

២- គុណនាមត្រូវមានវចនៈ លិង្គដូចនាមដែលគុណនាមត្រូវសម្ពន្ធបុលដែរ ជាដាច់ខាត ។

១- សត្វគោបុលបិត្តទីស្ងួតជាង-ហេតុនេះដែលនឹងថែទាំចិញ្ចឹមគោឲ្យបានធំធាត់បំរើន គេត្រូវធ្វើក្រោលវានៅទី

ខ្ពស់ស្គមមិនមានកក់ (មាស-រឿន)

២- រាជអាណាខេត្ត របស់ព្រះបាទអសោកមហារាជ

នោះ ធំទូលាយសម្បើមណាស់ ដិតគ្រប់អស់ដែនឥណ្ឌា

ទាំងមូល (ញ-ថែម)

សម្ពន្ធ

| | |
|---|---|
| ស្គមផាង | វិសេសគុណនាម ទបុំ. ឯក. វិសេសន៍របស់ទី ។ |
| ធំ-ធាត់-បំរីន | ទាំង៣បទនេះ បកតិគុណនាម បុំ. ឯក. វិសេសន៍ របស់គោ |
| ខ្ពស់-ស្គម | ទាំង ២ បទនេះ បកតិគុណនាម ទបុំ. ឯក. វិសេសន៍ របស់ទី |
| ធំទូលាយសម្បើម ណាស់ | អតិវិសេសគុណនាម ទបុំ. ឯក. វិសេសន៍ របស់រាជអាណាខេត្ត |

សិស្ស————មេរៀន————

គុណនាមមាន៣យ៉ាងគឺ:

១- បកតិគុណនាម = គុណដែលប្រាប់លក្ខណៈរបស់

នាមធម្មតា ។- ក្របីស្គម

២-វិសេសគុណនាម: គុណនាមដែលសំដែងលក្ខណៈ ប្លែកជាងបកតិគុណនាមបន្តិច ។

ឧ- ក្របីធំជាងគោ

វិសេសគុណនាមមានពាក្យនេះជាចំណាំ (ជាង ប្លែក វិសេស-លើស) ត្រូវនៅបន្ទាប់គុណនាម ។

៣- អតិវិសេសគុណនាម: គុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យវិសេសទៅទៀត ។

ឧ-នាវានេះ ធំអស្ចារ្យ

អតិវិសេសគុណនាម ត្រូវមានពាក្យនេះជាចំណាំ(បំផុត ណាស់-ក្រៃពេក-យន់-ក្សស-បណ្តាច់-បំឡេក) ត្រូវនៅបន្ទាប់គុណ

៤- គុណនាម ត្រូវជាបទវិសេសន៍របស់នាម ត្រូវមានលិង្គវចនៈ ដូចនាមដែលសម្ពន្ធប្ចូលដែរ ។

ការហាត់ ចូរសម្ពន្ធគុណនាមក្នុងប្រយោគខាងក្រោមនេះ

១– នៅនានាប្រទេស គេនិយមរាប់អានការអានសៀវភៅ សំខាន់ជាងការមើលកុន (ប–ឈុំ)

២- ក្អែកញីឈ្មោលមួយគូ សម្បុរខ្មៅរលើបយង់អាស្រ័យនៅលើដើមឈើមួយធំ ម្លប់ត្រឈឹងត្រឈៃ (ឱ.គ)

៣– ពស់នោះ តែងចាប់កូនតូចធំ ស៊ីជាអាហារ ៗ

៤– ក្អែកញីថា បុះបើពស់នេះ មានពិសខ្លាំងច្រើនជាងយើង តើយើងគិតធ្វើដូចម្ដេច?

ជំពូកទី ៤

មេរៀនទី ៨

## សម្ពន្ធកិរិយាសព្ទ

Analyse les verbes

គ្រូ មុនលោកគ្រូ-អ្នកគ្រូ បង្រៀនសម្ពន្ធដល់សិស្ស ត្រូវសង្កេតមើលកិរិយា ទាំង២នេះសិនគឺ

១– សកម្មកិរិយា កិរិយាសព្ទជំពូកនេះ ត្រូវមានបទកម្ម មកជួយបំពេញទើបកិរិយាសព្ទនោះមានសេចក្ដីពេញលេញ

ឧ– ខ្ញុំស៊ី

បើនិយាយថា ស៊ី មិនដឹងជាស៊ីអ្វី ដូច្នេះត្រូវបំពេញ បទកម្មមកទៀត

ឧ– ខ្ញុំស៊ីបាយ

ដូច្នេះទើបស្ដាប់បាន

២– អកម្មកិរិយា កិរិយានេះ ប្រើបានខ្លួនឯង មាន បទកម្មពេញគ្រប់គ្រាន់ខ្លួនឯង មិនឲ្យបញ្ចូលបទកម្មមកទេ

## ខ- ខ្ញុំលោត

កិរិយាស័ព្ទ លោត អាចស្ដាប់បាន

បំណា បទគុណដែលនៅជាប់ជាមួយអកម្មកិរិយា ច្រើនតែជាកិរិយាវិសេសន៍ទៅវិញ

### របៀបសម្ពន្ធ

បើប្រធានជាឯកវចនៈ ឬពហុវចនៈ កិរិយាស័ព្ទក៏ទៅតាមប្រធានដែរ ។

១- អ្នកគង្វាល វាយក្របីឥតត្រាប្រណី ហើយបង់ក្របីបង្អត់មិនឲ្យស៊ីស្មៅ

២- ពេលឈប់សំរាករៀន កូនសិស្សទាំងឡាយរត់លោតលេងយ៉ាងរីករាយ ។

---

### សម្ពន្ធ

| | |
|---|---|
| វាយ | សកម្មកិ. បឋមបុរស ឯកវចនៈ មានអ្នកគង្វាលជាប្រធាន |
| ចង | សកម្មកិ. បឋមបុរស ឯក. មានអ្នកគង្វាលជាប្រធាន |
| រត់,លោត,លេង | ទាំង ៣ នេះ អកម្មកិ. បឋមបុរស ពហុ. មានសិស្សទាំងឡាយជាប្រធាន |

សិស្ស______________ មេរៀន______________

កិរិយា ២ យ៉ាងគឺ

១– សកម្មកិរិយា គឺកិរិយាមានកម្មមិនគ្រប់គ្រាន់ត្រូវបញ្ចូលបទកម្មទើបបានសេចក្ដីស្ដាប់បាន ។

២– អកម្មកិរិយា កិរិយាដែលមានបទកម្មគ្រប់គ្រាន់ខ្លួនឯង

៣– កិរិយាស័ព្ទទាំង ២ នេះ មានវិធេយ្យៈទៅតាមប្រធាន

ការហាត់ ក) គូសបន្ទាត់កិរិយាស័ព្ទខាងក្រោមនេះ

១– ប្រុស-ស្រីភ្ញាក់ពីព្រលឹម ដួតក្បាលចំសំពោង នាំគ្នាទៅស្រែ (ប.ថែម)

២– ឯទន្សាយ លុះដល់ព្រលប់យប់ងងឹតគិតចង់ស៊ីស្រូវសំណាប ក៏ស្ទុះលោតប៉ូលទៅស៊ីពាល់តែម្ដង ។

៣– អ្នកអត្តពល ទាត់បាល់ ក្មេងក៏ឡើងដាន ។

៤– ក្មេងវេលានោះ គឺច្ចក់លោតបុះ លោតឡើង...

១)– ចូរសម្ពន្ធស័ព្ទ ក្នុងប្រយោគខាងក្រោមនេះ

analyser les mots

១– សត្វកណ្ដុរទាំងឡាយ អាស្រ័យនៅក្នុងទីមួយ មានសេចក្ដីក្ដៅក្រហាយលំបាក ដោយមេឆ្មាមួយតែងយាយី នឹងចេញរកស៊ីពុំបាន (ច. ឈុំ)

២– នៅពេលចូលឆ្នាំ វាសរសេរសំបុត្រមួយច្បាប់ផ្ញើ ទៅលោកគ្រូ សួរសេចក្ដីសុខទុក្ខដល់លោក ហើយនឹងជូនពរសព្វសាធុការដល់ក្រុមញាតិរបស់លោក សូមឲ្យលោកទាំងនោះ បានប្រកបនូវសុវត្ថិភាព តរៀងទៅ (គ. សៃត)

មេរៀនទី៩

## កាលនៃកិរិយាស័ព្ទ

### Temps du verbe

ឯ កាលក្នុងបាលី គេញែកកាលឲ្យល្អិតល្អណាស់ កាលធំមានតែ ៣ ដែរ ៗ ការរៀនសម្ពន្ធមុន ត្រូវបេះកាល ៣ ឲ្យស្អាតសិន ៗ

១-- បច្ចុប្បន្នកាល ពេលដែលមានក្នុងទីចំពោះមុខ ដែលកំពុងនិយាយ ឥឡូវនេះ ៗ បច្ចុប្បន្នកាល មានពាក្យ (កំពុង តែង ទើប...) នៅមុខកិរិយាស័ព្ទជាគ្រឿងសំគាល់

២--អតីតកាល កាលដែលកន្លងហួសទៅហើយ គឺ កាលដែលមានរួចមកពីថ្ងៃដែលបានប្រព្រឹត្តរួចទៅហើយ ពី ម្សិល ពីម្សិលម៉្ងៃ... ៗ កាលនេះត្រូវមានពាក្យថា ហើយ នៅបានកិរិយា គេត្រូវរៀងដូច្នេះ

បាន...(កិ).....ហើយ ៗ ...(កិ).....ហើយ ៗ

៣— អនាគតកាល  កាលដែលមិនទាន់មានមកដល់ គឺកាលដែលនៅខាងមុខ កម្មដែលយើងត្រូវប្រព្រឹត្តមិនទាន់បានធ្វើទេ តែមុខតែបានធ្វើក្នុងពេលខាងមុខ ។ កាលនេះត្រូវមានពាក្យថា (នឹង. . .) នៅមុខកិរិយាស័ព្ទ ។

បំណាំ ១— កុំច្រឡំនឹងសំរាប់ប្រាប់អនាគតកាល នឹងអាយតនិបាត

២— បច្ចុប្បន្នកាល ជួនកាលរៀងមកតែកិរិយាស័ព្ទទទេ មិនមានពាក្យអ្វីនៅមុខទេ

ឧ— កូនទៅបំការ (គ្មាន)

កូនកំពុងទៅបំការ (មាន)

របៀបសម្ព័ន្ធ  កាលបើគេសម្ពន្ធកិរិយាស័ព្ទហើយ គេត្រូវប្រាប់កាលក្លាម ។

១— ខ្ញុំកំពុងដើរទៅ(១) បានជួបនឹងអ្នកបរទេះ. . .

២— បងខ្ញុំ នឹងទៅបំពេញបេសកកម្ម

៣— អ្នកបរទេះ បានព្រួជួប្រោះហើយ ក៏ដើរទៅរកអ្នក

---

១— កុំច្រឡំថាអតីតកាល ព្រោះកិរិយាដើមឃ្លា ប្រាប់បច្ចុប្បន្នកាល

បររះទេះវិញៗ

សម្ពន្ធ

| | |
|---|---|
| កំពុងដើរទៅ | អកម្មកិ. បច្ចុប្បន្នកាល បឋមបុរស ឯកវចន. ខ្ញុំជាប្រធាន |
| នឹងទៅបំពេញ | សកម្មកិ. អនាគតកាល បឋមបុរស ឯកវចន. បងខ្ញុំជាប្រធាន |
| បានញ.. ហើយ | សកម្មកិ អតីតកាល បឋមបុរស ឯកវចន· |
| អ្នកបររទេះ | ជាប្រធាន |

សំស្ស ——— មេរៀន ———

១–បច្ចុប្បន្នកាល ពេលនៅកន្លងចំពោះមុខ ឥឡូវ ឥ-ឡូវនេះ

២– អតីតកាល ពេលដែលកន្លងហួសទៅហើយពីម្សិល ពីម្សិលម៉្ងៃ....

៣–អនាគតកាល ពេលដែលមិនទាន់មានមុខដល់គឺ(នៅខាងមុខ) ។ ត្រូវមានពាក្យ ‹ នឹង, នៅមុខកិរិយាស័ព្ទៗ

៤–ត្រូវសម្ពន្ធបន្ទាប់កិរិយាស័ព្ទ

ការហាត់ ក) ចូរសម្ពន្ធកិរិយាស័ព្ទខាងក្រោយនេះ

១– សិស្សកំពុងតែលេងក្នុងទីធ្លាសាលា ក្មេងម្នាក់ក៏ដើរមកវាយក្មេងតូចម្នាក់ ។

២– ខ្លាឃ្មុំមួយ កំពុងដេកក្រោមដើមពុទ្រា ។

៣– ខ្លាឃ្មុំខំងើបឡើងដើមពុទ្រា ក៏បែកអាឃាតថាអាដើមពុទ្រានេះ អញកំពុងដេកស្រួល ៗ ....

៤– ពីម្សិលមិញ សាស្ត្រាចារ្យបានឲ្យឱវាទដល់សិស្ស ហើយក្នុងទីបំពោះមុខចាងហ្វាងសាលា ។

៥– ស្អែកមា តាប៊ិតាខ្ញុំ នឹងអញ្ជើញទៅមើលប្រាសាទអង្គរ ។

១) ចូរសម្គាល់ពាក្យខាងក្រោមនេះ (នាម គុណនាម កិរិយា)

១– ដាំង កំពុងដុតដែកមួយបន្ទះឲ្យក្តៅក្រហមឆ្អៅ ។

២– ជាងឈើ បានឈូសកំណាត់ក្តារនេះយ៉ាងល្អ ហើយ គាត់វាយភ្ជាប់គ្នានឹងដែកគោល ធ្វើបាតហឹប (ប ផែម)

៣– មាន់រងាវហើយ កសិករលីនង្គ័លលើស្មា ដឹក

គ្រប់ពីក្រោយ ដើរឆ្ពោះទៅវាលស្រែ (គ-ស)

៤–ស្អែក គណៈបេសកកម្មខ្មែរ នឹងចេញដំណើរទៅសហរដ្ឋអាមេរិក ដើម្បីនឹងបំពេញមុខវិជ្ជាថែមទៀត ។

មេរៀនទី១០

## សម្ពន្ធបុរិសសព្វនាម

Analyse les Pronoms personnels

គ្រូ សព្វនាម មានមុខការដូចតែនាមដែរ សូមមើលទៅមេរៀនដែលមានរួចមកហើយ ។

បុរិសសព្វនាម មាន ៣ គឺ

១– ឧត្តមបុរិសសព្វនាម ពាក្យដែលគេប្រើជំនួសនាមដែលមានមករួចម្ដងហើយ គេមិនបាច់បញ្ចេញនាមនោះទៀត គេត្រូវប្រើឧត្តមបុរិសសព្វនាម

ឧ ខ្ញុំ មិនបានទៅទេ ។

ពាក្យត្រូវជំនួសគឺ(ខ្ញុំ ខ្ញុំបាទ អញ អាត្មាភាព អាត្មានខ្ញុំ)

២–មជ្ឈិមបុរិសសព្វនាម ពាក្យដែលគេត្រូវជំនួសនាមដែលគេត្រូវនិយាយ ដោយមិនបាច់យកនាមនោះមកថាទៀត

គេត្រូវប្រើមធ្យមបុរិសសព្វនាម

ខ វា យំប៉ុះ យើងវត់ចោលវា

ពាក្យត្រូវជំនួសគឺ (នាង លោក ទ្រង់ ព្រះអង្គ ឯង ហង អា អ្នក)

៣- បឋមបុរិសសព្វនាម ពាក្យដែលគេត្រូវជំនួសនាមដែលគេត្រូវនិយាយ តែគេមិនយកពាក្យនោះមកនិយាយទៀត គេត្រូវយកបឋមបុរិសសព្វនាមមកប្រើជំនួសវិញ ។

ខ ទ្រង់ ព្រះមេត្តាប្រោស

ពាក្យត្រូវជំនួសគឺ (វា គេ នាង លោក ព្រះអង្គ ទ្រង់)

របៀបសម្ពន្ធ បុរិសសព្វនាម ត្រូវសម្ពន្ធដូចនាមដែរ ហើយមុខងារក៏ដូចគ្នាទៀត

១- ខ្ញុំទៅសាលារៀន

២- ឯងដឹកវាផង

៣- វាយំហើយ

... ... ...

## សម្ពន្ធ

| | |
|---|---|
| ខ្ញុំ | ឧត្តមបុ. ឯក. ប្រធាននៃទៅ |
| ឯង | មជ្ឈិម. ឯក. ប្រធាននៃនឹង |
| វា | បឋម. ឯក. កម្មរបស់នឹង |
| វា | បឋម. ឯក. ប្រធានរបស់យំ |

សិស្ស ——— មេរៀន ———

ក) បុរិសសព្វនាម ៣ យ៉ាងគឺ

១– ឧត្តមបុរិសសព្វនាម ពាក្យដែលគេត្រូវប្រើជំនួសខ្លួនគេ ដែលគេមិនបានបញ្ចេញឈ្មោះគេ

២– មជ្ឈិមបុរិសសព្វនាម ពាក្យដែលគេត្រូវនិយាយជំនួស ពាក្យដែលគេត្រូវនិយាយទៅរកក្ថដ៏ទីចំពោះមុខ ៗ

៣- បឋមបុរិសសព្វនាម ពាក្យដែលប្រើជំនួសបុគ្គលដែលគេត្រូវនិយាយ ៗ

ខ) សព្វនាមមានមុខងារដូចនាមដែរ (លិង្គ-វចនៈ-ប្រធាន-កម្ម)

ការហាត់ ក) ចូរសម្ពន្ធបុរិសសព្វនាមក្នុងប្រយោគខាងក្រោមនេះ

១– ខ្លាឃ្មុំមិនយល់ទោសខ្លួន ក៏ឆ្លើយថារូបខ្ញុំនេះព្រះ-អង្គសាងឲ្យមានធ្មេញបន្ទុមដ៏មុត (គតិលោក)

២– ព្រះឥសូរក៏ត្រាស់ទៅឧដ្ឋវិញថា «ម្ដេចទៅឧដ្ឋ រូបកាយឯងសព្វថ្ងៃនេះស្រួលបួលហើយឬ... (គតិលោក)

៣– សត្វឧដ្ឋឆ្លើយថា «ព្រះអង្គរូបកាយខ្ញុំនេះមានកវែងអាចអើតស៊ីស្លឹកឈើខ្ពស់បាន (គតិលោក)

ខ) ចូរសម្ពន្ធស័ព្ទខាងក្រោមនេះ

១– នាយកនដឹងខ្លួនរត់ចេញពីក្រុង បញ្ចុះបញ្ចូលរាស្ត្រលើកទ័ពច្បាំងនឹងម្ចាស់ផែនដី (ល-សារុម)

២– បើថាខ្ញុំមិននិយាយស្មើមតិ ក្នុងកាលគួរមកដល់ហើយ នោះក៏រូបខ្ញុំមិនសមធ្វើជាមន្ត្រីដែរ (ប-ខាត់)

៣– ចចកទនក បានស្ដាប់សំដីចចកករជក និយាយហើយ អស់សំណើចសើចយឹកៗ ទើបនិយាយថា «នែមិត្ត!

បួរឯងនៅឲ្យស្ងៀមទៅកុំមាត់ថ្វី ហេតុដែលនាំឲ្យម្ចាស់យើងភ័យនោះ អញដឹងអស់ហើយ មិនគឺសំឡេងអ្វីដទៃផ្សេងទេ គឺសំរែកគោឧសភពេទ៌នោះឯង ឯគោឧសភត្រូវជាបំណីអាហារយើងផង ចាំបាច់និយាយដល់សីហ ធ្វើអ្វី (ប-ខាត់)

មេរៀនទី ១១

## សម្ពន្ធប្រយោគ

Analyse Logique

ក្រុ ប្រយោគបើសង្កេតទៅតាមបាលីមានប្រយោគ ៥ តែខ្ញុំសូមយកតែប្រយោគ ២ មកបង្រៀនសិន ចាំទៅថ្នាក់លើសឹមឲ្យរេបៈប្រយោគ ៣ ទៀត ។

១-ប្រយោគកត្តុ គឺប្រយោគដែលមានកិរិយាស័ព្ទធ្វើជាបទប្រធាន សំរេចខ្លួនឯងគឺធ្វើនូវអំពើផ្ទាល់ខ្លួនឯង ។

៖ មនុស្សលើបប

២-ប្រយោគកម្ម គឺប្រយោគដែលបង់កម្មសុះទៅធ្វើជាប្រធាន ហើយបទប្រធានដែលសំរេចនូវអំពើទៅធ្វើជាបទកម្មវិញ ។ ប្រយោគមានពាក្យថា (គឺ-ដែល) ដាក់នៅមុខគឺនាមជាអ្នកសំរេចនូវអំពើ ។

៖ ចបដែលមនុស្សលើ

ចំណាំ កុំច្រឡំគឺដែលគេខេសេចក្ដី

ខ សុទ្ធខគឺផ្ទៃ

របៀបសម្គាល់ ១ ក្នុងប្រយោគកម្ម គេត្រូវថា «អនកិហ៊ិតកម្ម» វិញបានត្រូវ ។

១– គ្រឹហាសនៈ ដែលព្រៃរុកខន្ទ្រាន (ប-ឈ្មោះ)

២– ខេមរជាតិជាន់នោះបានកសាងសេទាសនៈ ដ៏ល្អគួរស្ញប់ស្ញែង (ប-ឈ្មោះ)

—————————— សម្គាល់ ——————————

១– គ្រឹហាសនៈ ដែលព្រៃរុកខន្ទ្រាន ប្រយោគកម្ម
២– ខេមរជាតិជាន់នោះ... ដ៏ល្អគួរស្ញប់ស្ញែង ប្រយោគកត្ត

សិស្ស —————————— មេរៀន ——————————

ប្រយោគ ២ បែបគឺ

១– ប្រយោគកត្តុ បទប្រធានធ្វើអំពើខ្លួនឯង

២– ប្រយោគកម្ម បទកម្មធ្វើប្រធាន បទប្រធានទៅធ្វើ

កម្មវិញ ។

ចំណាំ ប្រយោគកម្ម តែងតែមានពាក្យថា ដែល, នឹង គឺ នៅមុខដែលធ្វើអំពើ ។

ខ ទានដែលបុគ្គលឲ្យ

ការហាត់ ក) ចូរសម្គាល់ប្រយោគខាងក្រោមនេះ

១– វេលាដែលផែនដីធ្វើចលនាបានមួយជុំ មានចំនួនម្ភៃបួនម៉ោង គឺមួយថ្ងៃនឹងមួយយប់ (ឈឹម-សំផុន)

២– អាហារ ដែលយើងបរិភោគ អាចធ្វើឲ្យយើងមានកំឡាំងហើយរស់នៅបាន (រ-គោរ៉ិច)

៣– អ្នកស្រីឆោតល្ងង់មិនបានពិចារណា ចាប់ដំបងវាយសំពងពពែស្ទើរស្លាប់ (ឌុ-ចាម)

ខ) ចូរសម្គាល់ស័ព្ទក្នុងប្រយោគខាងក្រោមនេះ

១– នៅក្បែរមាត់ត្រពាំង មនុស្សអង្គុយស្ទូចត្រីនៅក្រោមម្លប់ឈើដ៏ត្រជាក់ ។

២– ក្របីទាញនង្គ័ល ដោយសេចក្ដីលំបាក ក្រោមកំ

ដៅព្រះអាទិត្យ (ឌុ - គាម)

៣—មនុស្សម្នាក់ៗ មិនអាចរស់នៅម្នាក់ៗ ឯងបាន ដោយមិនបាច់ពឹងពាក់គ្នាទៅវិញទៅមកទេ ។

មេរៀនទី ១២

## អាយតនិបាត

ដើម្បីនឹងរៀនសម្ពន្ធឲ្យបានជ្រៅជ្រះ ត្រូវតែរៀនអាយ-តនិបាតទាំង៨ឲ្យចេះសិន ទើបអាចរៀនសម្ពន្ធទៅថ្នាក់ខ្ពស់ៗទៀតបាន ។ ចំពោះថ្នាក់បឋមសិក្សា ខ្ញុំជាគ្រូរៀនសម្ពន្ធត្រឹមប៉ុណ្ណោះសិនហើយ តែបើត្រូវការរៀនក្នុងអនុវិទ្យាល័យទៀត ត្រូវឲ្យចេះអាយតនិបាតថែមទៀត ឲ្យច្បាស់លាស់ដើម្បីឲ្យងាយដល់ពេលដែលឡើងទៅថ្នាក់លើ ៗ ។

ភាសាខ្មែរ ដូចជាសាំញាំបន្តិច មិនងាយនឹងសម្ពន្ធបើបំណែកបាលីគេមានវិភត្តិ ( déclinaison ) ងាយយល់ណាស់ គេគ្រាន់តែឃើញវិភត្តិ គេអាចជា ស័ព្ទនេះសម្ពន្ធចូលជាមួយនាម ជាមួយកិរិយា ។

អាយតនិបាតទាំង ៨ គឺ

១–បឋមវិភត្តិ Nominatif = រ (sujet)

២- ទុតិយាវិភត្តិ accusatif នូវ, កាន់, ញុាំង, អស់ ទឹង, ចំពោះ, Complément d'objet

៣- តតិយាវិភត្តិ instrumental ដោយ, ដោយនូវ តាម, ខាង, គឺ, ដែល, ហេតុ, ព្រោះ, ព្រោះតែ, មាន

Complément de moyen

៤- ចតុត្ថីវិភត្តិ datif ដល់, ដើម្បី, បំរុង, ទឹង, ចំពោះ complément d'attribution

៥- បញ្ចមីវិភត្តិ ablatif អំពី, ចាក, ជាង, ហេតុព្រោះ ព្រោះតែ

Complément de séparation

៦- ឆដ្ឋីវិភត្តិ génétif នៃ, របស់, កាល, កាលបើ កាលដែល, ដំនុំ, បណ្តា Complément de terminatif

៧- សត្តមីវិភត្តិ locatif ក្នុង, ឰដ៏, ត្រង់, នា, នាកាល កាលបើ, កាលដែល, ដំនុំ, និមិត្ត, បណ្តាល, លើ, ទៀប, ក្បែរ,

Complément circonstanciel de lieu

កាលបើរៀនចប់របៀបសម្ពន្ធនេះហើយ មុខជាឆាយយល់ដល់ទៅថ្នាក់លើទៀត ។

បើចង់ដឹងឲ្យពិស្ដារទៅទៀត សូមអានសម្ពន្ធខ្វះថ្នាក់ឆ្នាំទី ៦ និងទី ៥ ទី ៤ និង ៣ ទាំងបេជាតិទើបពិស្ដារជាងនេះទៅទៀត ។

១០៤ វិថីព្រះអង្គយុគន្ធរ
ភ្នំពេញ

តម្លៃ ១០រ